**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ...១៦៧...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# បែបបទក្នុងការជម្លៀសសាធារណជន
# ចេញពីកន្លែងដែលអាចមានគ្រោះថ្នាក់កើតឡើង

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីលក្ខខណ្ឌ និងវិធានការ ក្នុងការជម្លៀសសាធារណជនជាបណ្តោះអាសន្ន ក្នុងករណីដឹងថា មានគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

មាត្រា ២.-

គោលបំណង នៃអនុក្រឹត្យនេះ គឺ ដើម្បីធានាសុវត្ថិភាពសាធារណៈ និង ដើម្បីបង្ការ ទប់ស្កាត់គ្រោះមហន្តរាយ ដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិ ។

មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់ រាល់ការជម្លៀសសាធារណជន ចេញពីទីតាំងសាធារណៈ ទីតាំងឯកជន ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

និយមន័យជម្លៀសក្នុងអនុក្រឹត្យនេះ គឺ ការបញ្ចៀសចេញជាបណ្តោះអាសន្ន ពីតំបន់ ទីតាំង ឬ លំនៅឋានណាមួយ ដែលបម្រុង ឬ នឹងអាចកើតមានគ្រោះថ្នាក់ ដោយអាវុធ គ្រឿងផ្ទុះ និង គ្រាប់-រំសេវ ឆ្ពោះទៅរកតំបន់ ឬ ទីតាំងដែលធានាសុវត្ថិភាព ។

## ជំពូកទី ២
## លក្ខខណ្ឌ និង វិធានការក្នុងការជម្លៀស

មាត្រា ៥.-

ការតម្រូវឱ្យសាធារណជនចេញ ជាបណ្តោះអាសន្ន ពីតំបន់ ទីតាំង ឬ លំនៅឋានណាមួយត្រូវមានហេតុផលច្បាស់លាស់ ដែលអះអាងដោយអ្នកជំនាញ ឯកទេសបញ្ជាក់ថា គ្រោះថ្នាក់អាចនឹងកើតមានឡើង។

មាត្រា ៦.-

ក្នុងករណីគ្រោះថ្នាក់នោះអាចកើតឡើងភ្លាមៗ សមត្ថកិច្ច ឬ អាជ្ញាធរដែនដីនៅទីនោះ ត្រូវចាត់វិធានការផ្សព្វផ្សាយជូនដំណឹង ដល់សាធារណជនជាបន្ទាន់។ ទន្ទឹមនោះសមត្ថកិច្ច ឬ អាជ្ញាធរដែនដីនៅទីនោះ ត្រូវចាត់ការដោះស្រាយកាត់បន្ថយ ឬ បំបាត់ប្រសិទ្ធភាព នៃមហន្តរាយ ការពារផលប្រយោជន៍ទាំងឡាយ រួមទាំងការសង្គ្រោះ និងត្រូវរាយការណ៍ជាបន្ទាន់ មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង/ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា ៧.-

ក្នុងករណីគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ សមត្ថកិច្ច ឬ អាជ្ញាធរដែនដី ត្រូវធ្វើសេចក្តីរាយការណ៍ មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង/ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយភ្ជាប់ជាមួយនូវសេចក្តីបញ្ជាក់អំពីមូលហេតុ ឬ ការអះអាងពីអ្នកជំនាញ ឯកទេស និង ផែនការត្រូវដោះស្រាយកាត់បន្ថយ ឬបំបាត់ប្រសិទ្ធភាព នៃមហន្តរាយ ផែនការការពារផលប្រយោជន៍ និង សង្គ្រោះ រយៈពេលចេញ

និង វិលត្រឡប់ ទីតាំងដែលត្រូវកំណត់ឱ្យស្នាក់នៅបណ្តោះអាសន្ន ព្រមទាំងចំនួនប្រជាពលរដ្ឋ ដែលអាចរងផលប៉ះពាល់ ។

មាត្រា ៨.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវចាត់អញ្ជើញតំណាងក្រសួង ស្ថាប័ន រោងចក្រ សហគ្រាស ឬ ប្រជាពលរដ្ឋ ដើម្បីចាត់ការប្រមែប្រមូល រាល់មធ្យោបាយចាំបាច់យកទៅជួយសង្គ្រោះ ដូចជា ការដឹកជញ្ជូន ការស្នាក់នៅ គ្រឿងឧបភោគ បរិភោគ ថវិកា សំដៅធានាសុខុមាលភាព សុវត្ថិភាព និង សន្តិសុខ ។

មាត្រា ៩.-

សមត្ថកិច្ច ឬ អាជ្ញាធរដែនដី ត្រូវធ្វើទំនាក់ទំនងរកទីសាធារណៈ គ្រឹះស្ថានសាធារណៈ ឬ ទីតាំងឯកជន ដែលមានចម្ងាយផុតពីគ្រោះភ័យ ដើម្បីឱ្យជនរងផលប៉ះពាល់ ដែលជម្លៀសចេញពីតំបន់គ្រោះថ្នាក់ ស្នាក់អាស្រ័យនៅជាបណ្តោះអាសន្ន ។

សមត្ថកិច្ច ឬ អាជ្ញាធរដែនដី និង ជនរងផលប៉ះពាល់ ដែលបានស្នាក់អាស្រ័យនៅជាបណ្តោះអាសន្ន ត្រូវធានាថែរក្សាទ្រព្យសម្បត្តិ ផលប្រយោជន៍ស្របច្បាប់របស់ទីសាធារណៈ គ្រឹះស្ថានសាធារណៈ ឬ ទីតាំងឯកជនទាំងនោះ ។

ក្រោយការដោះស្រាយករណីគ្រោះថ្នាក់ចប់សព្វគ្រប់ សមត្ថកិច្ច ឬ អាជ្ញាធរដែនដី ត្រូវរៀបចំជូនជនរងផលប៉ះពាល់ បានវិលត្រឡប់ទៅរស់នៅដើមខ្លួនវិញ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលរាជធានី អភិបាលខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ